**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៨១០......សហវ

**ក្រសួងពាណិជ្ជកម្ម**

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើតក្រុមការងារដើម្បីរៀបចំយន្តការ

## ការចុះបញ្ជីពាណិជ្ជកម្ម និងពន្ធដាររួមរវាងក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសារពើពន្ធ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពី វិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម និងច្បាប់វិសោធនកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-យោងប្រកាសលេខ២៩៩ ចបព.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

-យោងប្រកាសលេខ៣០០ ចបព.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការចុះបញ្ជីពាណិជ្ជកម្មសារឡើងវិញ ក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម

-យោងសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.ពហ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី លើករណីសំណើសុំគោលការណ៍របស់ក្រសួងពាណិជ្ជកម្ម សុំអនុវត្តជម្រើសទី១ "ក្រោមក្របខ័ណ្ឌដំបូលតែមួយ"

-យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងាររួមសម្រាប់រៀបចំ និងបង្កើតយន្តការចុះបញ្ជីរួមរវាងក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពាណិជ្ជកម្ម និងចុះបញ្ជីពន្ធដារ និងដើម្បីគ្រប់គ្រងឱ្យកាន់តែប្រសើរឡើងនូវទិន្នន័យសហគ្រាសដែលបានចុះបញ្ជី ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. ឯកឧត្តម **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ | សហប្រធាន |
| ២. ឯកឧត្តម **សុខ សុភ័ក្ត្រ** | អនុរដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម | សហប្រធាន |
| ៣. ឯកឧត្តម **ម៉ក់ ខុសតា** | អគ្គនាយកសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤. ឯកឧត្តម **ហេង សុខណាង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធាន |
| ៥. លោកស្រី **ម៉ុម ថាណា** | អគ្គនាយកសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦. លោក **ខិម តារាបុទ្ធិ** | ប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧. លោក **ហ៊ាន ត្រេង** | ប្រធាននាយកដ្ឋានសេវាអ្នកជាប់ពន្ធនិងបំណុលពន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៨. លោក **គង់ សុខហេង** | អនុប្រធាននាយកដ្ឋានសេវាអ្នកជាប់ពន្ធនិងបំណុលពន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៩. លោក **លឹម ជីលុច** | អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១០. លោក **ស្រី ម៉ាន់ ឆារី** | អនុប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១. លោក **ស៊ូ ម៉ង់** | អនុប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១២. លោក **គន់ ឌីរ៉ង់** | ប្រធានការិយាល័យព័ត៌មាន និងទំនាក់ទំនងសាធារណៈ | លេខាធិការ |
| ១៣. លោក **ខ៊ែត ឆៃលាង** | ប្រធានការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជី នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៤. លោក **កែវ ម៉ង់តា** | ប្រធានការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជី នៃនាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុល នៃអគ្គនាយកដ្ឋានពន្ធដារ | លេខាធិការ |

**ប្រការ ២.-**

ក្រុមការងារនេះមានភារកិច្ចរៀបចំយន្តការចុះបញ្ជីរួមរវាងក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចខាងក្រោម÷

- រៀបចំយន្តការ នីតិវិធី លិខិតបទដ្ឋាននានា ដើម្បីចុះបញ្ជីពាណិជ្ជកម្ម និងចុះបញ្ជីពន្ធដាររួមគ្នា
- រៀបចំយន្តការតភ្ជាប់ប្រព័ន្ធ និងកម្មវិធីការងារ ដើម្បីអនុវត្តកិច្ចការងារចុះបញ្ជីរួម
- រៀបចំគម្រោងបច្ចេកទេស និងថវិកាដែលត្រូវការ សម្រាប់រៀបចំនិងដាក់អនុវត្តយន្តការចុះបញ្ជីរួម
- រៀបចំកិច្ចប្រជុំជាប្រចាំក្នុងរយៈពេលមួយខែម្តង ឬតាមការចាំបាច់ តាមការអញ្ជើញរបស់សហប្រធាន។ ក្រុមការងារអាចអញ្ជើញជំនាញការ និងអ្នកជំនាញរបស់តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ចូលរួមផ្តល់យោបល់លើការងារពាក់ព័ន្ធ។

**ប្រការ ៣.-**

គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់អង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចក្នុងប្រការ១ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០១៦

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប៉ាន-សូរស័ក្តិ

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៣ "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ